# មាតាបិតាក៏រាប់ផងដែរ

## ជួយកូនរបស់លោកអ្នកនៅក្នុង – ការវាស់ប្រវែង និងក្រឡាផ្ទៃ

កុមាររៀនចេះនៅពេលណាគេលេង។ គេអាចរៀនចេះអំពីប្រវែង និងក្រឡាផ្ទៃតាមរយៈការសាកល្បង និងការធ្វើខុសជាមួយរបស់ទាំងឡាយដូចជាដុំខ្សែបូ វត្ថុគំរូធ្វើពីដីឥដ្ឋ និងរបស់ក្មេងលេងសំរាប់សាងសង់។

ក្នុងកាលគេកំពុងលេងកុមារចាប់ផ្តើមកត់សម្គាល់អំពីទំហំ និងរូបរាងរបស់ របៀបដាក់ផ្គុំរបស់ចូលគ្នា របៀបគេដាក់របស់គរពីលើគ្នាប្រវែង និងបណ្តោយនៃរបស់។ កុមារត្រូវការលើកទឹកចិត្តឲ្យចេះរុករក ហើយលៃលកចាត់ចែងរបស់ ហើយនិយាយអំពីរបស់ដែលគេរុករកឃើញ។

## តើកុមាររៀនចេះវាស់ប្រវែង និងក្រឡាផ្ទៃដោយរបៀបណា?

ជាដំបូងកុមាររៀនចេះបង្កើតនូវការដឹងយល់អំពីរង្វាស់ តាមរយៈការប្រៀបធៀបរបស់។ គេអាចចាប់លើកដុំពីរ ហើយនិយាយប្រាប់ថាដុំមួយខ្ពស់ជាង ឬវែងជាងដុំមួយទៀត។ បន្ទាប់ភ្លាមនោះមក គេក៏ចាប់ផ្តើមប្រៀបធៀបរបស់ច្រើនជាងពីរ។

កុមារត្រូវការរៀន ហើយដកពិសោធន៍ជាមួយសម្ភារៈផ្សេងៗ និងរបស់ទាំងឡាយសំរាប់វាស់ជាមួយ មុននឹងគេអាចចាប់ផ្តើមប្រើរង្វាស់ *ត្រឹមត្រូវ* ដូចជាម៉ែត្រ ឬសង់ទីម៉ែត្រ។ ឧទាហរណ៍ គេត្រូវការវាស់ប្រវែងតុដោយប្រើដង្កៀបហាលខោអាវស្លាបព្រា ឬស្បៀវភៅ ឬចង្អាមដៃមុននឹងចាប់ប្រើបន្ទាត់។



Khmer


Curriculum K–12 Directorate, © NSW Department of Education

# មាតាបិតាក៏រាប់ផងដែរ

## តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?

- ប្រើដុំម្សៅលុញធ្វើជារូប "ពស់" ពីរដែលមានប្រវែងខុសគ្នា។ និយាយអំពីរូបពស់មួយ "ខ្លីជាង "ហើយរូបពស់មួយទៀត "វែងជាង"។
- លុញធ្វើរូបពស់ពីរប្រវែងស្មើគ្នាចេញពីដុំម្សៅ។ យករូបពស់មួយបត់ធ្វើជារាងបត់បែន។ សួរកូនរបស់លោកអ្នកថាតើ *រូបពស់មួយណាមានប្រវែងវែងជាង?*



- គូសដានដៃ ឬជើងរបស់កូនលោកអ្នកពីលើបន្ទះក្ដារក្រាស់ រួចហើយកាត់ឲ្យចេញជារូបរាង។ ប្រើរូបរាងនោះដើម្បីវាស់ប្រវែងរបស់ទាំងឡាយដូចជាតុ ឬគ្រែគេងរបស់កូនរបស់លោកអ្នក។ មុននឹងលោកអ្នកវាស់ លើកទឹកចិត្តកូនរបស់លោកអ្នកឲ្យប៉ាន់ស្មានថាតើគ្រែគេងនោះមានប្រវែងប៉ុន្មានដៃ ឬជើង។
- រុញរូបកូនឡានតាមបណ្ដោយផ្លូវជំរាលមួយ ហើយវាស់មើលថាតើវាបានធ្វើដំណើរចំនួនប្រវែងប៉ុន្មានកូនឡាន។
- ដើរជុំវិញរបស់ រួចហើយនិយាយអំពីចំនួនជំហានប៉ុន្មានដែលវាត្រូវការ ដើម្បីដើរឲ្យបានមួយជុំ។
- កត់ចុះការធំលូតលាស់របស់កូនលោកអ្នក នៅពីលើរង្វាស់កម្ពស់។
- ប្រៀបធៀបកម្ពស់នៃសមាជិកគ្រួសារ ហើយសួរថាតើនរណា "ខ្ពស់ជាង" និង "ទាបជាង"។
- ប្រើឈើដើម្បីវាស់ចម្ងាយ រវាងកូនរុក្ខជាតិនៅពេលដាំ។
- វាស់ក្រឡាផ្ទៃនៃរានហាលក្រោយផ្ទះ ឬក្រឡាផ្ទៃតុដោយប្រើសន្លឹកសារពត៌មាន។ រាប់ចំនួនសន្លឹកសារពត៌មានប៉ុន្មានដែលត្រូវការ ដើម្បីគ្របឲ្យបានពេញផ្ទៃ។


Curriculum K–12 Directorate, © NSW Department of Education

# មាតាបិតាក៏រាប់ផងដែរ



- គូសរាងបត់បែន ឬយកខ្សែបត់ធ្វើជាងរាងបត់បែននៅពីលើក្រដាស រួចហើយយកជ័រការលាបពីលើវា។ ផាត់ពណ៌ផ្នែកនៃផ្ទៃ "ខាងក្នុង" ទាំងនោះ។
- លាតសន្លឹកសារពត៌មានពីលើកំរាល។ រាប់ចំនួនសៀវភៅដែលអាចដាក់ពេញពីលើសន្លឹកសារពត៌មាននោះ។
- នៅពេលខ្ចប់អំណោយ និយាយអំពីទំហំនៃក្រដាស ហើយសួរថាតើក្រដាសនោះធំ ហើយវែងល្មមគ្រប់គ្រាន់ឬទេ។
- និយាយអំពីទំហំនៃកំរាលតុដែលត្រូវការ ដើម្បីគ្របពីលើតុ ឬឡាន។
- សម្លឹងមើលផ្ទៃគ្របដណ្តប់ដែលបង្ហាញប្រាប់នៅពីលើកំប៉ុងថ្នាំលាប។ សួរអំពីចំនួនថ្នាំប៉ុន្មានកំប៉ុងដែលលោកអ្នកត្រូវការ។
- ប្រមូលក្រដាសពណ៌ចោល និងកំប៉ុងទទេ ឬប្រអប់ធ្វើពីក្រដាសរឹង ដូចជាប្រអប់អាហារធញ្ញជាតិ។ កូនរបស់លោកអ្នកអាចបង្កើតជាវត្ថុគំរូពណ៌ ដោយលាបជ័រការពីលើក្រដាស ដើម្បីយកទៅគ្របឲ្យបានពេញពីលើប្រអប់ក្រដាសរឹង ឬកំប៉ុងនោះ។
- បង្ហាញប្រាប់កូនរបស់លោកអ្នកនូវឧទាហរណ៍ខ្លះៗនៃកិច្ចការបំណះតូចៗ រួចហើយនិយាយអំពីគំនូររូបរាងទាំងឡាយ។ លើកទឹកចិត្តឲ្យកូនរបស់លោកអ្នកឲ្យបង្កើតគំនូររូបរាងដោយប្រើដុំ ក្រដាសចោល និងក្រដាសពណ៌។


Curriculum K–12 Directorate, © NSW Department of Education